# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបុណ្យព្រះយេស៊ូប្រសូតនៅគិរីរម្យ
# ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨
## *យើងទៅជារោងព្រះយេស៊ូដ៏មានជីវិត*

អត្ថបទទី១៖ អស ៩,១-៦
អត្ថបទទី២៖ ទត ២,១១-១៤
ដំណឹងល្អ៖ លក ២,១-១៤

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងឃើញយាយៗ មីងៗមួយចំនួន និងបងប្អូនគ្រីស្តបរិស័ទមួយចំនួន ជាមួយលោកតាទាំងពីរដែលចូលរួមអភិបូជានៅក្នុងព្រះវិហារនេះ។ យើងបានស្តាប់អត្ថបទទីពីរ «**ព្រះជាម្ចាស់បានសម្តែងព្រះហឫទ័យប្រណីសន្តោសមក ដើម្បីសង្គ្រោះមនុស្សទាំងអស់**» នេះជាមូលហេតុយើងមកទីនេះ។ យើងបានជួបជុំគ្នានៅមុខរោងព្រះយេស៊ូ យប់នេះជាយប់ពិសេស ដោយសារ យើងឃើញយ៉ាងជាក់ស្តែងផ្ទាល់ភ្នែក ព្រះជាម្ចាស់បានសម្តែងព្រះហឫទ័យប្រណីសន្តោស។ ខ្ញុំចង់សួរទៅកាន់បងប្អូន **តើនៅពេលនេះយើងបានឃើញអ្វីខ្លះ? តើយើងបានស្តាប់ឮអ្វីខ្លះ? តើយើងបានហិតក្លិនអ្វីខ្លះ?**

ពេលយើងនៅមុខព្រះយេស៊ូប្រសូត យើងបានមើលម្តាយនាងម៉ារី បានមើលឃើញប៉ាប៉ាលោកយ៉ូសែប បានមើលឃើញកូនង៉ែតមួយដែលប្រសូតថ្មីៗឈ្មោះយេស៊ូ។ អេម៉ាណូអែល មានន័យថាព្រះជាម្ចាស់គង់នៅជាមួយយើង នេះឈ្មោះយេស៊ូ។ យើងបានមើលឃើញអីទៀត? សត្វ! មូលហេតុអីមានសត្វ? ដោយសារព្រះយេស៊ូកើតនៅក្នុងក្រោលគោ។ គ្រូគង្វាល ហោរាចារ្យ យើងបានឃើញនេះ! យើងបានឃើញដូចជារឿងធម្មតាមែនទែន អត់មានអ្វីអស្ចារ្យប៉ុន្មានទេ ប្លែកប ដោយសារកើតក្នុងក្រោលគោ **ទីពីរ**ព្រះនាងម៉ារី និងលោកយ៉ូសែប ធ្វើដំណើរឆ្ងាយ ធ្វើដំណើរពីភូមិណាសារ៉ែតដល់បេថ្លេហិម។ នេះជាអ្វីដែលយើងមើលឃើញផ្ទាល់ភ្នែករបស់យើង គ្រួសារមួយដែលអស់កម្លាំង ប៉ុន្តែពោរពេញដោយអំណរសប្បាយ ដោយសារកូនកើតមក។

យើងបានស្តាប់ឮសំឡេងទេវទូត ដោយសារទេវទូតបានចុះពីលើស្ថានបរមសុខ និងបានច្រៀងអស់ពីកម្លាំង អស់ពីដួងចិត្ត "**ព្រះជាម្ចាស់ប្រសូតហើយ! ព្រះជាម្ចាស់យាងមកដើម្បីណែនាំឲ្យមនុស្សទាំងអស់ពោរពេញដោយសេចក្តីសុខសាន្ត**"។ យើងស្តាប់ក្រុមទេវទូត ដែលច្រៀងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ អម្បាញ់មិញពេលយើងហៃចូលយើងខិតខំបញ្ចូលសំឡេងយើងល្មមៗ ប៉ុន្តែបញ្ចូលជាមួយសំឡេងក្រុមទេវទូតទាំងអស់។ សំឡេងពិសេស ដោយសារសំឡេង ណែនាំឲ្យយើងពោរពេញទៅដោយសេចក្តីសង្ឃឹម ចាប់ពីពេលនេះតទៅពិភពលោករបស់យើងមានពន្លឺមួយ ដែលណែនាំឲ្យយើងមានសេចក្តីសង្ឃឹម។

ហិតក្លិន ក្នុងក្រោលគោយើងធុំក្លិនអាចម៍គោ! ពេលហោរាចារ្យមកថ្វាយបង្គំគេយកគ្រឿងក្រអូប។ ដូច្នេះយប់ដ៏សុខសាន្តនេះយើងហិតក្លិនក្រអូបដូចធូប ដែលជាសញ្ញានៃវត្តមានរបស់ព្រះជាម្ចាស់នៅលើផែនដីនេះ។

ដូច្នេះអ្វីដែលយើងបានមើលឃើញ យើងបានស្តាប់លឺ យើងបានស្រង់ក្លិន ណែនាំឲ្យយើងពោរពេញដោយសេចក្តីសង្ឃឹមនៅពេលនេះ។ ខ្ញុំនឹកឃើញ ២០ឆ្នាំដែលមកដល់ប្រទេសកម្ពុជា នៅឆ្នាំ២០០២ លោកតាទាំងពីរខិតខំធ្វើដំណើរទៅដល់ព្រះវិហារសន្តីម៉ារីញញឹមចំការទៀង នៅតាមផ្លូវពិបាក។ ពេលទៅដល់ចំការទៀងគាត់ដូរពណ៌អស់ហើយ ឡើងពណ៌ក្រហម។ ខ្ញុំចាំ ២០០៣ មកដល់ទីនេះ ពេលមកដល់ផ្ទះលោកតា ខ្ញុំបានឃើញយាយៗមកច្រើនណាស់ យាយៗថា អូហ៍ពេទ្យយេស៊ូមកដល់ហើយ។ គេមកបង្ហាញជង្គង់ផង ដៃផង និងមានខ្លះឈឺសរសៃ ឈឺចង្កេះ សុំឲ្យពេទ្យជួយផង។ ឯខ្ញុំខ្មែរក៏ស្ទើរភ័យណាស់! ខ្លាចអស់ហើយនៅពេលនោះ បែកញើសអស់រលីង។

ពីឆ្នាំ២០០៣ដល់ឆ្នាំ២០០៦ មិនទាន់មានអ្វីសោះនៅទីនេះ យើងពិបាកក្នុងការប្រកាសដំណឹងល្អ ដោយសារយាយៗតាៗ អត់សូវគាំទ្រយើងប៉ុន្មានទេ។ មានយុវជនដែលមកពិបាកណាស់សម័យមុន គេនិយាយតាមមេក្រូជូនកាលគេថា៖ "**ប្រសិនបើចូលសាសនាយេស៊ូ នៅពេលមានអំណោយយើងអត់ជួយទេ**" និងហាមតាយាយកុំឲ្យកូនចៅចូលសាសនាយេស៊ូ។ ឆ្នាំ២០០៦ យប់បុណ្យព្រះយេស៊ូប្រសូត ជាពេលវេលាពិសេស ជាលើកទីមួយដែលយើងបានធ្វើបុណ្យព្រះយេស៊ូប្រសូតលើដីហ្នឹង។ យើងបានសម្រេចចិត្តយប់នេះ យើងអញ្ជើញតាយាយមួយចំនួនដើម្បីបង្ហាញសេចក្តីស្រឡាញ់ ដែលកូនចង់មានចំពោះតាយាយ និងការគោរព ហើយនៅពេលនោះ លោកតា លោកយាយមក។ ចាប់ពីពេលនោះមក ព្រះសហគមន៍របស់យើង រីកចម្រើនយ៉ាងស្រួល ដោយសារលោកតាលោកយាយបានយល់ថា សាសនាយេស៊ូមិនអាក្រក់ទេសាសនាយេស៊ូល្អណាស់ គោរពគ្នាទៅវិញទៅមក គោរពព្រះពុទ្ធសាសនា គោរពលោកតាលោកយាយ គោរពចាស់ទុំ ចេះរួមរស់ជាគ្រួសារមួយ ជួយឲ្យកូនៗយើងមានការសិក្សា ដូចជាមានសាលាមត្តេយ្យជាដើម។ ជួយឲ្យប្អូនៗយើងមានការអប់រំ ដើម្បីចេះរស់នៅយ៉ាងសមរមនៅក្នុងសង្គមប្រកបដោយយុត្តិធម៌ ប្រកបដោយសីលធម៌ ប្រកបដោយចិត្តស្រឡាញ់ និងគោរពចាស់ទុំ។ សន្តិតេរេសាមានការអស្ចារ្យនៅយប់បុណ្យព្រះយេស៊ូប្រសូតនៅឆ្នាំ១៨៨៦ ប៉ុន្តែយើងមានការអស្ចារ្យនៅយប់បុណ្យព្រះយេស៊ូប្រសូតនៅឆ្នាំ២០០៦។ ចាប់ពីពេលនោះមកព្រះសហគមន៍របស់យើងមានជីវិតនៅក្នុងសេរីភាព បង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយលោកអាចារ្យ បង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះចៅអធិការវត្ត និងជាមួយតាយាយ។ ពីពេលនោះមកខ្ញុំឃើញ

យាយចូលវិហាររាល់អាទិត្យ មកស្ដាប់ថា តើលោកឪពុកទេសនាត្រឹមត្រូវដើម្បីអប់រំកូនខ្ញុំ ឬនាំឲ្យកូនខ្ញុំវង្វេង? ក្រោយមកយាយៗថាត្រឹមត្រូវ អប់រំកូនឲ្យខ្ញុំរីកចម្រើន និងទទួលជីវិត។

ដូច្នេះថ្ងៃនេះយើងត្រូវតែអរព្រះគុណព្រះជាម្ចាស់ ដោយនឹកឃើញអ្វីដែលយើងត្រូវការមើលឃើញ អ្វីដែលយើងត្រូវការស្ដាប់ឮ និងអ្វីដែលយើងត្រូវការស្រង់ក្លិន។ ដើម្បីអ្វី? យើងត្រូវគិតទាំងអស់គ្នាដែលជាយុវជន យុវនារី ដែលជាកូនក្មេង យើងធ្វើយ៉ាងម៉េចដើម្បីណែនាំឲ្យការអស្ចារ្យដែលយើងបានមើលឃើញ គឺព្រះយេស៊ូផ្ទាល់។ ការអស្ចារ្យដែលយើងបានស្ដាប់ឮ គឺទេវទូតណែនាំឲ្យយើងទទួលសេចក្ដីសុខសាន្ត។ ការអស្ចារ្យដែលយើងបានស្រង់ គឺក្លិនក្រអូបនៃធូបដែលណែនាំឲ្យយើងនឹកឃើញព្រះជាម្ចាស់គង់នៅជាមួយយើង។ យើងត្រូវតែណែនាំឲ្យមនុស្សជាច្រើនទទួលស្គាល់ ដើម្បីឲ្យសង្គម ភូមិ ជីវិតរបស់យើងទៅជាជីវិតថ្មី។ ជាង២០០០ឆ្នាំមុនព្រះយេស៊ូយាងមក ដើម្បីឲ្យពិភពរបស់យើង ទៅជាពិភពថ្មី។ ពិតមែនជាង២០០០ឆ្នាំ មនុស្សនៅក្នុងពិភពលោកទាំងមូលគោរពកុមារហ្នឹងដែលជាព្រះជាម្ចាស់ផ្ទាល់ និងណែនាំជីវិតរបស់យើងទៅជាជីវិតថ្មី។ ហេតុនេះហើយសម្រាប់ឆ្នាំ២០១៩ ដែលជិតចាប់ផ្ដើមហើយ យើងត្រូវការគិត តើយើងត្រូវតែធ្វើអ្វីខ្លះ ដើម្បីណែនាំឲ្យសង្គមខ្ញុំ ព្រះសហគមន៍ខ្ញុំ ជីវិតខ្ញុំ ទៅជាជីវិតសង្គម ព្រះសហគមន៍ដែលស្អាតទៅៗ ពោរពេញដោយក្ដីស្រឡាញ់ថែមទៀត ដើម្បីឲ្យព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ ដែលកើតនៅក្នុងយប់នេះ អាចបន្តកើតពេញមួយឆ្នាំខាងមុខនេះ។

ដូច្នេះថ្ងៃនេះខ្ញុំសូមអញ្ជើញបងប្អូនទាំងអស់ ឲ្យទៅជាព្រះនាងម៉ារីបន្តិច ឲ្យទៅជាលោកយ៉ូសែបបន្តិច ឲ្យទៅជាគ្រួសារដ៏វិសុទ្ធ។ ខ្ញុំអញ្ជើញបងប្អូនទាំងអស់ ដើម្បីឲ្យយើងទៅជាទេវទូតដើម្បីច្រៀងកោតសរសើរសិរីរុងរឿងរបស់ព្រះជាម្ចាស់។ យើងសូមអញ្ជើញបងប្អូនទាំងអស់ឲ្យទៅជាធូបដែលមានក្លិនក្រអូប ដើម្បីណែនាំអំណរសប្បាយរបស់ព្រះអង្គទៅគ្រប់ទីកន្លែងនៅក្នុងភូមិរបស់យើង។ ប្រសិនបើយើងទៅជារោងព្រះយេស៊ូប្រសូតដ៏មានជីវិត មានន័យថា ប្រសិនបើយើងទៅជានាងម៉ារី ប្រសិនបើយើងទៅជាលោកយ៉ូសែប ប្រសិនបើយើងទៅជាក្រុមទេវទូតប្រសិនបើយើងទៅជាក្លិនក្រអូប ប្រសិនបើយើងជោគជ័យ ដូចយប់ហ្នឹង យើងបានឃើញប្រជាជន ក្រុមគង្វាល ហោរាចារ្យ គេបានមកថ្វាយបង្គំ។ ដូច្នេះយប់នេះ យើងមានប្រជាជនដែរ យើងមានបងប្អូនទាំងអស់ដែលគេចង់មកថ្វាយបង្គំដែរ ប៉ុន្តែស៊ីសងយើង តើចេះស្វាគមន៍ តើយើងចេះលើកទឹកចិត្ត តើយើងចេះទទួលគេ? ទាំងអស់គ្នា គេដើរតាមផ្កាយមួយ ដោយសារសង្គមបច្ចុប្បន្ននេះនរណាក៏ចង់មានសេចក្ដីសុខ និងដើរតាមផ្កាយមួយដើម្បីមានទស្សនៈគោលដៅដើម្បីទៅមុខនៅក្នុងជីវិត។ ផ្កាយនៅមាន ផ្កាយគឺព្រះជាម្ចាស់ផ្ទាល់ដែលមនុស្សទាំងអស់កំពុងស្វែងរកកំពុងឈ្វេងយល់។ ប៉ុន្តែពេលគេមកដល់កន្លែងហ្នឹង មានន័យថាពេលគេមកដល់វិហារយើង តើ

គេរកឃើញមនុស្សដែលស្វាគមន៍គេ ដូចព្រះនាងម៉ារី និងលោកយ៉ូសែប បានស្វាគមន៍ក្រុមគង្វាល ហោរាចារ្យ និងក្រុមទេវទូតឬទេ? តើគេរកឃើញមុខពោរពេញដោយភាពញញឹម ដើម្បីជួយលើកទឹកចិត្តមនុស្សដែលកំពុងមានទឹកភ្នែកយ៉ាងច្រើន? តើគេរកឃើញដៃដែលយើងបើកយ៉ាងទូលំទូលាយដើម្បីស្វាគមន៍យ៉ាងរាក់ទាក់ និងយ៉ាងកក់ក្តៅដល់បងប្អូនដែលមកពីចម្ងាយ និងមកពីជិត? តើគេរកឃើញចិត្តគំនិត ពោរពេញដោយសេចក្តីស្រឡាញ់ ដើម្បីលើកទឹកចិត្តអ្នកដែលគ្មានទីពឹង គ្មានសេចក្តីសង្ឃឹម ទាំងអ្នកក្រក្រី ទាំងអ្នកជំងឺ? តើគេរកឃើញក្លិនក្រអូបដើម្បីមានកម្លាំងសារជាថ្មី និងសេចក្តីសង្ឃឹមសារជាថ្មីទេ?

ប្រសិនបើយើងជោគជ័យនេះ នៅក្នុងឆ្នាំ២០១៩ យើងទៅជាព្រះនាងម៉ារី យើងទៅជាលោកយ៉ូសែប យើងទៅជាទេវទូត និងយើងទៅជាធូបយ៉ាងក្រអូប។ ខ្ញុំជឿថា ព្រះសហគមន៍របស់យើង អាចទទួលស្វាគមន៍មនុស្សយ៉ាងច្រើន ដើម្បីទទួលជីវិតថ្មី និងដើម្បីធ្វើដំណើរបន្តទៅទៀត និងមានសេចក្តីសង្ឃឹម។

ដូច្នេះថ្ងៃនេះ យើងអធិដ្ឋានដើម្បីឲ្យយប់នេះ ដែលជាយប់ដ៏សុខសាន្ត ដែលព្រះយេស៊ូប្រសូតហើយ ទៅជាយប់មួយយ៉ាងពិសេស ដែលយើងទាំងអស់គ្នាសាងសង់រោងព្រះយេស៊ូ ដ៏ស្អាតបំផុត។ ដូច្នេះសម្រាប់យើងយប់នេះ ឲ្យយើងទៅជារោងព្រះយេស៊ូដ៏មានជីវិត យើងបន្តទៅជានាងម៉ារី ទៅជាលោកយ៉ូសែប ទៅជាទេវទូត ទៅជាផ្កាយ ទៅជាធូបដើម្បីស្វាគមន៍បងប្អូនអស់ពេញមួយឆ្នាំ។ ដូច្នេះឲ្យយើងគិត ធ្វើយ៉ាងម៉េចឲ្យព្រះសហគមន៍របស់យើងទៅជាមហាគ្រួសារ ដ៏សុខសាន្តរបស់ព្រះជាម្ចាស់។ ពិតមែន ព្រះយេស៊ូប្រសូតហើយ ពិតមែនព្រះយេស៊ូយាងមកដើម្បីណែនាំឲ្យយើងទទួលពន្លឺមួយនៅក្នុងជីវិត និងចែករំលែកពន្លឺហ្នឹង។ ជយោ ព្រះយេស៊ូប្រសូត! អាម៉ែន៕